សេចក្តីប្រកាសព័ត៌មាន

# S&P ដំឡើងចំណាត់ថ្នាក់ឥណទាន ‘B+’ ដល់ ABA

ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ (ABA Bank) ដែលជាធនាគារពាណិជ្ជធំទីបីនៅកម្ពុជា និងជាបុត្រសម្ពន្ធរបស់ធនាគារជាតិកាណាដា សូមប្រកាសនៅថ្ងៃនេះថា ចំណាត់ថ្នាក់ឥណទានរយៈពេលវែងរបស់ខ្លួនដែលទទួលបានពីភ្នាក់ងារវាយតម្លៃអន្តរជាតិឈ្មោះ Standard & Poor’s (S&P) Global Ratings ត្រូវបានដំឡើងពីកម្រិត ‘B’ ទៅ ‘B+’ ជាមួយនឹងទស្សនវិស័យស្ថិរភាព។

“យើងពិតជារីករាយណាស់ ដែលទទួលបានការដំឡើងចំណាត់ថ្នាក់ឥណទានពី S&P ព្រោះវាឆ្លុះបញ្ចាំងពីដំណើរការល្អរបស់យើង និងបញ្ជាក់ពីជំហររឹងមាំរបស់ ABA នៅក្នុងទីផ្សារ” នេះបើតាមប្រសាសន៍របស់លោក Zhiger Atchabarov ប្រធានផ្នែកប្រតិបត្តិការអន្តរជាតិរបស់ធនាគារ ABA។ “នេះគឺជាលទ្ធផលនៃការអនុវត្តយុទ្ធសាស្រ្តអាជីវកម្មត្រឹមត្រូវរបស់យើង ដែលផ្តល់អត្ថប្រយោជន៍ដល់អតិថិជន និងម្ចាស់ភាគហ៊ុន” លោកបានបន្ថែម។

អ្នកជំនាញរបស់ S&P ចាត់ទុកសមត្ថភាពនៃការគ្រប់គ្រង និងប្រព័ន្ធឌីជីថលរបស់ធនាគារ ABA ថាមានគុណសម្បត្តិល្អក្នុងការប្រកួតប្រជែង រួមជាមួយនឹងការគាំទ្រពីសម្ពន្ធធនាគារជាតិកាណាដាផងដែរ។

“យើងបានដំឡើងចំណាត់ថ្នាក់របស់យើងដល់ធនាគារ ABA ដោយផ្អែកលើសម្ការៈរបស់ធនាគារ និងការកើនឡើងចំណែកទីផ្សារនៃប្រាក់កម្ចីនិងប្រាក់បញ្ញើ រួមនឹងការទទួលបានប្រាក់ចំណេញលើសពីមធ្យម។ បច្ចុប្បន្នធនាគារ ABA គឺជាធនាគារធំលំដាប់ទីបីនៅកម្ពុជា ហើយបណ្តាញធុរកិច្ចរបស់ខ្លួនគ្របដណ្តប់អតិថិជនទាំងនៅក្នុងទីក្រុងនិងជនបទ ក៏ដូចជាប្រព័ន្ធឌីជីថលឈានមុខគេនៅក្នុងទីផ្សារផងដែរ។ តាមទស្សនៈរបស់យើង គុណសម្បត្តិដ៏មានភាពប្រកួតប្រជែងរបស់ធនាគារ ទំនងជានឹងបន្តគាំទ្រដល់ស្ថិរភាពអាជីវកម្មរយៈពេលវែងបាន” នេះបើយោងតាមបច្ចុប្បន្នភាពនៃការស្រាវជ្រាវរបស់ S&P។

“បណ្តាញធុរកិច្ចរបស់ ABA នៅទូទាំងប្រទេស និងវត្តមានដ៏រឹងមាំរបស់ខ្លួន ក្នុងការផ្តល់កម្ចីដល់អាជីវកម្មខ្នាតតូច សហគ្រាសខ្នាតតូចនិងមធ្យម (MSME) នឹងបន្តគាំទ្រដល់ជំហរអាជីវកម្មរបស់ខ្លួន។ ធនាគារ ABA បាននិងកំពុងពង្រីកប្រតិបត្តិការរបស់ខ្លួនយ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ 2010 ជាពិសេសនៅក្នុងផ្នែក MSME ។ យើងប៉ាន់ស្មានឃើញថា ចំណែកទីផ្សាររបស់ធនាគារ ABA មានដល់


Head Office
No. 141, 146, 148 and 148 ABCD Preah Sihanouk Blvd,
and No. 15 and 153 ABC, Street 278, Sangkat Boeung Keng Kang 1,
Khan Boeung Keng Kang, Phnom Penh, Kingdom of Cambodia
Tel: (+855) 23 225 333
info@ababank.com
www.ababank.com
Fax: (+855) 23 216 333
P.O. Box: 2277
SWIFT: ABAAKHPP

ទៅប្រហែលជា 10 ភាគរយ សម្រាប់ប្រាក់កម្ចី និងប្រហែលជា 12 ភាគរយ សម្រាប់ប្រាក់បញ្ញើ នេះបើគិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ 2019” អ្នកវិភាគរបស់ S&P បានបន្ថែម។

ទស្សនវិស័យស្ថិរភាពក៏ឆ្លុះបញ្ចាំងពីការយល់ឃើញ ដែលថាធនាគារ ABA នឹងគ្រប់គ្រងកំណើនប្រាក់កម្ចី និងប្រាក់បញ្ញើយ៉ាងឆាប់រហ័សប្រកបដោយនិរន្តរភាព ហើយនឹងបន្តរាយការណ៍អំពីគុណភាពទ្រព្យសម្បត្តិល្អ នៅក្នុងបរិយាកាសប្រតិបត្តិការដែលមានហានិភ័យខ្ពស់របស់កម្ពុជា។

ភ្នាក់ងារវាយតម្លៃអន្តរជាតិ S&P បានផ្តល់ចំណាត់ថ្នាក់ឥណទានកម្រិត ‘B’ ដល់ធនាគារ ABA នៅក្នុងឆ្នាំ 2017 និងរក្សាចំណាត់ថ្នាក់នេះដដែលនៅក្នុងឆ្នាំ 2018។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩

ធនាគារ ABA

**អំពី S&P Global Ratings**

ជាមួយការផ្តល់ចំណាត់ថ្នាក់ឥណទានដ៏លេចធ្លោប្រមាណជាង 1លាន ដល់ស្ថាប័នរដ្ឋាភិបាល, សាជីវកម្ម, វិស័យហិរញ្ញវត្ថុ, ក្រុមហ៊ុនហិរញ្ញវត្ថុនិងមូលបត្រអន្តរជាតិ S&P Global Ratings គឺជាទីភ្នាក់ងារផ្តល់ចំណាត់ថ្នាក់ឥណទានឈានមុខកម្រិតពិភពលោក។ ការវិភាគហានិភ័យឥណទាន ការស្រាវជ្រាវ និងទិន្នន័យនានានៃស្ថាប័ននេះ ជួយគាំទ្រដល់ការរីកចម្រើននៃតម្លាភាព និងសន្ទនីយភាពទីផ្សារលើពិភពលោក។ S&P Global Ratings មានអ្នកជំនាញប្រមាណជាង 1,500 ក្នុង 28 ប្រទេស លើពិភពលោក។ មានទីស្នាក់ការកណ្តាលស្ថិតនៅ ទីក្រុងញ៉ូយ៉ក សហរដ្ឋអាមេរិក។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ www.spratings.com។

ABA BANK
NATIONAL BANK OF CANADA GROUP

Head Office

No. 141, 146, 148 and 148 ABCD Preah Sihanouk Blvd,
and No. 15 and 153 ABC, Street 278, Sangkat Boeung Keng Kang 1,
Khan Boeung Keng Kang, Phnom Penh, Kingdom of Cambodia

Tel: (+855) 23 225 333
info@ababank.com
www.ababank.com

Fax: (+855) 23 216 333
P.O. Box: 2277
SWIFT: ABAAKHPP